# សេចក្តីប្រកាសព័ត៌មាន

## សិទ្ធិមនុស្ស៖ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ត្រឡប់មកកម្ពុជា

ហ្សឺណែវ (ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១) - អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្រ្តាចារ្យ **ស៊ូយ៉ា ប្រាសាទ ស៊ូប៊ែឌី** នឹងបំពេញទស្សនៈកិច្ចផ្លូវការលើកទីបួន មកកាន់កម្ពុជា ចាប់ពីថ្ងៃទី ១៥ ដល់ ២៤ ខែកុម្ភៈ ឆ្នាំ២០១១។

លោកស៊ូប៊ែឌីបាននិយាយថា "បេសកកម្មនេះមានគោលដៅដើម្បីតាមដានលើអនុសាសន៍ របស់ខ្ញុំស្តីពីមុខងាររបស់តុលាការ* ធ្វើការវាយតំលៃលើភាពរីកចំរើន ដែលសម្រេចបានលើការដកបទបរិហាកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ និង ការបង្កើតនូវយន្តការអចិន្រ្តៃយ៍មួយសម្រាប់កិច្ចសន្ទនារវាងរដ្ឋាភិបាល និង សង្គមស៊ីវិល ព្រមទាំងសិក្សាលើការងាររបស់អង្គនីតិបញ្ញត្តិ នៅក្នុងបរិបទនៃការវាយតំលៃជាបន្តរបស់ខ្ញុំលើស្ថាប័នគ្រឹះនានា ដែលដើរតួនាទីក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស"។

នៅកំឡុងទស្សនៈកិច្ចរបស់លោក អ្នកជំនាញការឯករាជ្យ ដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីធ្វើការវាយតំលៃ និង រាយការណ៍អំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នឹងចូលរួមពិភាក្សាផងដែរ លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល និង លើបញ្ហាទំនាស់ដីធ្លី និង ការបណ្តេញចេញ។"

កំឡុងពេលស្ថិតនៅប្រទេសកម្ពុជា លោក ស៊ូប៊ែឌី នឹងជួបជាមួយអាជ្ញាធររដ្ឋាភិបាលនានា អង្គនីតិបញ្ញត្តិ ក្រុមសង្គមស៊ីវិល តំណាងនានានៃទីភ្នាក់ងារអង្គការសហប្រជាជាតិ ម្ចាស់ជំនួយ និង ក្រុមអ្នកការទូតនានា។

អ្នករាយការណ៍ពិសេសធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកផ្សេងៗ ដើម្បីជំរុញដល់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យនេះ។ លោកបំពេញទស្សនៈកិច្ច ឬ បេសកកម្មជាទៀងទាត់ មកកាន់កម្ពុជា និង រាយការណ៍ប្រចាំឆ្នាំ ដល់ក្រុមប្រឹក្សាសន្តិសុខ។ ការិយាល័យ OHCHR ផ្ដល់ឲ្យលោកនូវជំនួយខាងបរិក្ខារ និង បច្ចេកទេស។

សេចក្ដីសង្កេតពីបេសកកម្មនេះ នឹង ដាក់បញ្ចូលក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេស ដើម្បីដាក់ជូនសម័យប្រជុំលើកទី១៨ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

**(*):** អនុសាសន៍នានារបស់អ្នករាយការណ៍ពិសេសៈ
http://cambodia.ohchr.org/EN/PagesFiles/Reports/SR-SRSG-Reports.htm

**ចប់**

*លោក ស៊ូយ៉ា ប្រាសាទ ស៊ូប៊ែឌី គឺជាសាស្ត្រាចារ្យច្បាប់មួយរូបនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស លោក ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សតែងតាំងជាអ្នករាយការណ៍ពិសេសក្នុងឆ្នាំ២០០៩ ។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកស្ថិតនៅឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ និងបំពេញការងារក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់ ។*

*សំរាប់ព័ត៌មានបន្ថែមអំពីអាណត្តិ និងការងាររបស់អ្នករាយការណ៍ពិសេស សូមមើល៖*
*http://cambodia.ohchr.org/EN/PagesFiles/SpecialRapporteurIndex.htm*

*វិបសាយរបស់ OHCHR – កម្ពុជា ៖*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សំរាប់ព័ត៌មានបន្ថែម និង **សំណើរព័ត៌មាន** សូមទំនាក់ទំនង៖*
*នៅភ្នំពេញ៖ មកកញ្ញា Zoe Latumbo (Tel: +855 12 790 178/ Email:zlatumbo@ohchr.org ឬ លោក ទូច ហួន (Tel: +855 012 476 493 / email: htouch@ohchr.org).*
***នៅ**ហ្សឺណែវ៖ កញ្ញា* Maureen Teo (Tel: + 41 22 928 9632 / email: mteo@ohchr.org).